# គោលការណ៍ឯកជនភាពជាសកល

## 1. អំពីគោលការណ៍នេះ

ក្រុមហ៊ុន Sumitomo Electric Group (“យើង” “ពួកយើង” ឬ “របស់យើង”) បានបង្កើតគោលការណ៍ឯកជនភាពជាសាកលនេះ (“គោលការណ៍” នេះ) ក្នុងគោលបំណងដំណើរការទិន្នន័យផ្ទាល់ខ្លួន និងការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីពាក់ព័ន្ធរបស់យើងឲ្យបានត្រឹមត្រូវ (ជារួមហៅថា “អ្នក”)។

គោលការណ៍នេះពន្យល់ពីរបៀបដែលយើងដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដោយផ្អែកទៅលើច្បាប់ដែលពាក់ព័ន្ធនឹងការដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក។ តាមច្បាប់ការពារទិន្នន័យជាធរមាន និងគោលការណ៍នេះ យើងសូមប្ដេជ្ញាគ្រប់គ្រងទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកឲ្យមានសុវត្ថិភាព និងសមស្របដោយយកចិត្តទុកដាក់ក្នុងការបន្ទទប់ស្កាត់ការប្រើប្រាស់ ការបង្ហាញព័ត៌មាន ការកែប្រែដែលគ្មានការអនុញ្ញាតជាដើមនៃទិន្នន័យផ្ទាល់ខ្លួនអំពីអ្នក។

អ្នកអាចស្ថិតក្រោមគោលការណ៍ជាក់លាក់ដែលផ្ដល់ដោយបណ្ដាក្រុមហ៊ុន Group របស់យើង (ដូចដែលបានកំណត់ខាងក្រោម) និងគោលការណ៍ជាក់លាក់ចំពោះផលិតផល ឬសេវាកម្មមួយចំនួនរួមគ្នាជាមួយគោលការណ៍នេះ។ គោលការណ៍ជាក់លាក់ទាំងនេះត្រូវដាក់គោលការណ៍នេះជំនួសកម្រិតដែលប្រការបានកំណត់ក្នុងគោលការណ៍ទាំងនេះផ្ទុយនឹងប្រការដែលមានចែងក្នុងគោលការណ៍នេះ។

ជាពិសេស ប្រសិនបើច្បាប់ណាមួយរបស់ប្រទេស តំបន់ ឬរដ្ឋខាងក្រោមអាចអនុវត្តបាន គោលការណ៍ជាធរមានខាងក្រោមក៏ត្រូវអនុវត្តរួមគ្នាជាមួយគោលការណ៍នេះផងដែរ។

- ជប៉ុន៖ គោលការណ៍ឯកជនភាពរបស់ប្រទេសជប៉ុន
- តំបន់សេដ្ឋកិច្ចអឺរ៉ុប (EEA)/ចក្រភពអង់គ្លេស៖

  គោលការណ៍ឯកជនភាពរបស់ចក្រភពអង់គ្លេស និង EEA
- រដ្ឋកាលីហ្វ័រញ៉ា៖ ច្បាប់បន្ថែមសម្រាប់ច្បាប់ស្តីពីសិទ្ធិឯកជនភាពរដ្ឋកាលីហ្វ័រញ៉ា

គេហទំព័ររបស់យើងអាចមានតំណភ្ជាប់ទៅ និងមកពីគេហទំព័រភាគីទីបី។ គេហទំព័រភាគីទីបីទាំងនេះ និងសេវាកម្មណាមួយដែលអាចចូលប្រើប្រាស់បានតាមរយៈពួកគេ គឺមានគោលការណ៍ឯកជនភាពផ្ទាល់ខ្លួនរបស់ពួកគេ។ យើងមិនទទួលខុសត្រូវចំពោះការអនុវត្តឯកជនភាពរបស់ភាគីទីបីណាមួយឡើយ។ យើងលើកទឹកចិត្តអ្នកឲ្យយល់ដឹងអំពីរឿងនេះ នៅពេលអ្នកចាកចេញពីគេហទំព័ររបស់យើង និងដើម្បីអានគោលការណ៍ឯកជនភាពដែលអាចអនុវត្តចំពោះគេហទំព័រភាគីទីបីទាំងនេះ។

## 2. ទិន្នន័យផ្ទាល់ខ្លួនដែលទទួលបានដោយយើង

ប្រភេទទិន្នន័យផ្ទាល់ខ្លួនដែលទទួលបានដោយយើងមានដូចខាងក្រោម៖

- ទិន្នន័យអត្តសញ្ញាណ និងទំនាក់ទំនង

  ឈ្មោះ អាយុ ថ្ងៃខែឆ្នាំកំណើត យេនឌ័រ មុខរបរ អាសយដ្ឋាន ប្រទេសដែលរស់នៅ និងព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងព័ត៌មានលម្អិតទំនាក់ទំនង ដូចជាលេខទូរសព្ទ អាសយដ្ឋានអ៊ីមែល និងគណនីប្រព័ន្ធផ្សព្វផ្សាយសង្គម

- ទិន្នន័យផលិតផល និងសេវាកម្ម

ព័ត៌មានទាក់ទងនឹងផលិតផល និងសេវាកម្មដែលអ្នកបានទិញ (រួមទាំងផលិតផល និងសេវាកម្មដែលអ្នកចង់ទិញ) (រួមទាំងលេខសម្គាល់ផលិតផល ព័ត៌មានលម្អិតនៃគំរូផលិតផល ព័ត៌មានទាក់ទងនឹងការធានា ព័ត៌មានទាក់ទងនឹងស្ថានភាព និងការប្រើប្រាស់ផលិតផល ព័ត៌មានទីតាំង ប្រវត្តិសេវាកម្ម និង ហាងលក់ទំនិញ)

- ទិន្នន័យប្រាស្រ័យទាក់ទង

ព័ត៌មានលម្អិតទាក់ទងនិងមតិ សំណើ ចម្ងល់ ការឆ្លើយតបការស្ទង់មតិ និងព័ត៌មានផ្សេងទៀតរបស់អ្នក ដែលអ្នកបានផ្តល់

- ទិន្នន័យបច្ចេកទេស

ទិន្នន័យបច្ចេកទេសរួមមានទិន្នន័យចូលប្រើ អាសយដ្ឋានអ៊ីនធឺណិតប្រូតូកូល (IP) ទិន្នន័យចូលរបស់អ្នក ប្រភេទនិងកំណែរបស់កម្មវិធីរុករក ការកំណត់តំបន់ពេលវេលានិងទីតាំង ប្រភេទនិងកំណែរបស់កម្មវិធីជំនួយរុករក ប្រព័ន្ធប្រតិបត្តិការនិងកម្មវិធី និងបច្ចេកវិទ្យាផ្សេងទៀតនៅលើឧបករណ៍ដែលអ្នកប្រើដើម្បីចូលប្រើប្រាស់គេហទំព័រនេះ

- ទិន្នន័យប្រើប្រាស់

ព័ត៌មានអំពីរបៀបដែលអ្នកប្រើគេហទំព័រ ផលិតផល និងសេវាកម្មរបស់យើង

- ទិន្នន័យទីផ្សារ

SUMITOMO ELECTRIC GROUP

ចំណូលចិត្តរបស់អ្នកក្នុងការទទួលបានទីផ្សារពីយើង ឬភាគីទីបីដែលចូលរួមដោយយើង និងចំណូលចិត្តប្រាស្រ័យទាក់ទងរបស់អ្នក។

- ព័ត៌មានទាក់ទងនឹងកម្មវិធី

  ព័ត៌មានទាក់ទងនឹងបទពិសោធន៍ ការអប់រំ និងសិទ្ធក្នុងការពិនិត្យធ្វើការប្រសិនបើអ្នកធ្វើការឱ្យយើង

- ព័ត៌មានទាក់ទងនឹងបុគ្គលដែលមាន ឬទទួលបាន ដើម្បីសម្រេចបាននូវគោលបំណងក្នុងការដំណើរការទិន្នន័យផ្ទាល់ខ្លួនដែលបានកំណត់នៅក្នុងផ្នែកទី 4 និង

- ព័ត៌មានដែលយើងផ្តល់ជូននូវសេចក្តីជូនដំណឹងដាច់ដោយឡែក។

យើងនឹងមិនទទួលបាន ឬប្រើប្រាស់ព័ត៌មានរសើបដែលបញ្ចេញទិន្នន័យរបស់អ្នកទាក់ទងនឹងសុខភាព ទិន្នន័យហ្សែន ទិន្នន័យពាក់ព័ន្ធនឹងទំនោរផ្លូវភេទរបស់អ្នកជាដើម លុះត្រាតែបានផ្តល់ឱ្យនូវច្បាប់ និងបទប្បញ្ញត្តិ ឬអ្នកយល់ព្រមឱ្យយើងធ្វើដូច្នេះ។

អ្នកអាចនឹងត្រូវបានតម្រូវឱ្យផ្តល់ជូនយើងនូវទិន្នន័យមួយចំនួន ព្រោះការផ្តល់ទិន្នន័យផ្ទាល់ខ្លួនត្រូវតម្រូវដោយលក្ខន្តិកៈ ឬកិច្ចសន្យា ឬដោយសារមូលហេតុផ្សេងទៀត។ ក្នុងស្ថានភាពនេះ ប្រសិនបើអ្នកមិនផ្តល់ជូននូវទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកទេ យើងប្រហែលជាមិនអាចផ្តល់សេវារបស់យើងជូនអ្នកបានទេ។

## 3. របៀបដែលយើងប្រមូលទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក

SUMITOMO ELECTRIC GROUP

យើងអាចនឹងទទួលព័ត៌មានផ្ទាល់ខ្លួនដូចដែលបានរៀបរាប់ខាងលើដោយផ្ទាល់ពីអ្នក តាមរយៈភាគីទីបី ដូចជាអ្នកម៉ៅការ ដៃគូអាជីវកម្ម និងអ្នកផ្តល់សេវាតាមបណ្តាញសង្គម (រួមមាន Facebook និង Google) ហើយតាមរយៈផលិតផល និងសេវាកម្មដែលបានផ្តល់ជូនដោយយើងផងដែរ។

ពិសេសជាងនេះទៅទៀត យើងប្រមូល និងដំណើរការទិន្នន័យផ្ទាល់ខ្លួននៅខាងក្រោមអំពីអ្នកដែលបានមកពីប្រភពនីមួយៗនៅខាងក្រោម៖

1. ព័ត៌មានដែលអ្នកផ្តល់ជូនយើង

   នេះរួមបញ្ចូលព័ត៌មានអំពីអ្នកដែលអ្នកផ្តល់ជូនមកយើងតាមរយៈទម្រង់បែបបទសាកសួរនៅលើគេហទំព័ររបស់យើង ឬដោយការប្រាស្រ័យទាក់ទងជាមួយយើង មិនថាតាមអ៊ីមែល ស្រោមសំបុត្រ ឬតាមទម្រង់ផ្សេងទៀត។

2. ព័ត៌មានដែលភាគីទីបីផ្តល់ជូនយើង

   នេះរួមបញ្ចូលព័ត៌មានអំពីអ្នកដែលភាគីទីបីផ្តល់ជូនមកយើងតាមរយៈទម្រង់បែបបទសាកសួរនៅលើគេហទំព័រយើង ឬដោយការប្រាស្រ័យទាក់ទងយើង មិនថាតាមអ៊ីមែល ស្រោមសំបុត្រ ឬតាមទម្រង់ផ្សេងទៀត។

3. **ព័ត៌មានដែលយើងប្រមូលពីអ្នកដោយស្វ័យប្រវត្តិ**

   នៅពេលអ្នកចូលទៅគេហទំព័រយើង គេហទំព័រនោះប្រមូលយកប្រភេទទិន្នន័យជាក់លាក់អំពីអ្នកដោយស្វ័យប្រវត្តិ។ ប្រភេទនៃទិន្នន័យទាំងនេះរួមមានកំណត់ហេតុចូលប្រើ, ការចូលប្រើបណ្តាញ (ឬក៏អាចហៅថាគីកសែល), ខូគី ។ល។ ប្រភេទនៃទិន្នន័យទាំងអស់នេះអាចនឹងនៅសល់ក្នុងកំព្យូទ័ររបស់អ្នក ហើយបន្តប្រមូលទិន្នន័យ។

SUMITOMO ELECTRIC GROUP

## 4. គោលបំណងនៃការដំណើរការទិន្នន័យផ្ទាល់ខ្លួន

ទិន្នន័យផ្ទាល់ខ្លួនដែលយើងបានប្រមូល ត្រូវបានដំណើរការសម្រាប់តែបុគ្គលិកដែលមានការអនុញ្ញាត សម្រាប់កិច្ចការដាក់លាក់ក្នុងគោលបំណងដូចខាងក្រោម និងវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិជាធរមានប៉ុណ្ណោះ។

1. ទិន្នន័យផ្ទាល់ខ្លួនរបស់អតិថិជន អ្នកផ្គត់ផ្គង់ អ្នកម៉ៅការ ដៃគូអាជីវកម្ម ឬអ្នកប្រើប្រាស់គេហទំព័រ (ជារួមហៅថា “ដៃគូអាជីវកម្ម”)

- ការផ្សព្វផ្សាយផលិតផល និងសេវាកម្មរបស់យើងរួមមានការផ្តល់ព័ត៌មានដែលពាក់ព័ន្ធ (ដូចជាការចែកចាយកាតាឡុក)
- ការលក់/ការផ្គត់ផ្គង់ផលិតផល និងសេវាកម្មរបស់យើង និងជំនួយអតិថិជន
- ការអភិវឌ្ឍផលិតផល និងសេវាកម្មរបស់យើង
- ការធ្វើទីផ្សារដោយផ្ទាល់ទៅកាន់ដៃគូអាជីវកម្មនាថ្ងៃអនាគត និងបច្ចុប្បន្នទាក់ទងនឹងផលិតផល ការផ្តល់ជូន ការផ្សព្វផ្សាយ រង្វាន់ កម្មវិធី និងសេវាកម្មដែលមានផ្តល់ជូន
- ការផ្ទៀងផ្ទាត់នៃសិទ្ធិទទួលបាន និងការផ្តល់រង្វាន់ ពាក់ព័ន្ធនឹងការផ្សព្វផ្សាយសម្រាប់ដៃគូអាជីវកម្ម

- ការវិភាគអំពីប្រវត្តិរុករករបស់ដៃគូអាជីវកម្មដែលពួកគេបានផ្តល់មកយើងតាមរយៈគេហទំព័រ និងបណ្តាញសង្គមរបស់យើង និងព័ត៌មានផ្សេងទៀតរបស់ដៃគូអាជីវកម្ម ដោយហេតុនេះការផ្តល់ឲ្យពួកគេជាមួយព័ត៌មានស្តីពីផលិតផលដែលបំពេញតាមចំណូលចិត្ត និងរសនិយមរបស់ពួកគេ
- ការវិភាគលើចំនួននៃការចូលប្រើប្រាស់ទៅកាន់ទំព័រដើមដែលបានរៀបចំឡើងតាមរយៈការផ្សាយពាណិជ្ជកម្មរបស់យើង ដោយហេតុនេះទើបមានការខិតខំកែលម្អខ្លឹមសារនៃការផ្សាយពាណិជ្ជកម្ម និងទីកន្លែងផ្សាយពាណិជ្ជកម្ម
- ការបំពេញគោលបំណងអាជីវកម្ម ឬពាណិជ្ជកម្មណាមួយផ្សេងទៀតតាមការណែនាំរបស់ដៃគូអាជីវកម្ម ឬដោយការជូនដំណឹង និង/ឬការយល់ព្រមនេះ
- ការអនុវត្តកិច្ចសន្យាជាមួយដៃគូអាជីវកម្ម
- ការចូលរួមក្នុងការចរចារអាជីវកម្ម កិច្ចប្រជុំ ឬទម្រង់ផ្សេងទៀតនៃការប្រាស្រ័យទាក់ទងជាមួយដៃគូអាជីវកម្ម (រួមទាំងការថតសំឡេង និងថតកាសែតវីដេអូនៃខ្លឹមសាររបស់កិច្ចប្រជុំបែបនេះ ។ល។)
- ការឆ្លើយតបទៅនឹងមតិយោបល់ សំណួរ និងការស្នើសុំពីដៃគូអាជីវកម្ម ការផ្តល់សេវាគាំទ្រនៅពេលក្រោយ និងការអនុវត្តផ្សេងទៀតនៃសេវាកម្ម ដែលស្នើសុំដោយដៃគូអាជីវកម្ម
- ការស្ទង់មតិកម្រងសំណួររបស់ដៃគូអាជីវកម្ម និងការវិភាគលទ្ធផលរបស់ខ្លួន

**2.** ទិន្នន័យផ្ទាល់ខ្លួនរបស់ម្ចាស់ភាគហ៊ុន

- ការអនុវត្តសិទ្ធ និងការអនុវត្តកាតព្វកិច្ចស្ថិតក្រោមច្បាប់ ឬបទប្បញ្ញត្តិជាធរមានដែលមានចែងក្នុងនោះ
- ការផ្តល់សេវាកម្ម
- ការអនុវត្តនៃវិធានការណ៍ផ្សេងៗសម្រាប់ម្ចាស់ភាគហ៊ុន
- ការគ្រប់គ្រងព័ត៌មានម្ចាស់ហ៊ុនទាក់ទងនឹងបទបញ្ញត្តិ និងបទបញ្ជា រួមបញ្ចូលការបង្កើតមូលទិន្នន័យ

**3.** ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដាក់ពាក្យស្នើសុំការងារ

- ការផ្តល់ព័ត៌មានការងារទៅអ្នកដាក់ពាក្យសុំ និងការប្រាស្រ័យទាក់ទងជាមួយពួកគេទាក់ទងនឹងនីតិវិធីជ្រើសរើស ដោយផ្ទាល់ ឬតាមរយៈសកលវិទ្យាល័យ ឬភ្នាក់ងារការងាររបស់ពួកគេ
- ការពិចារណាថាតើត្រូវជួលអ្នកដាក់ពាក្យសុំឬអត់
- ការគ្រប់គ្រងលើអ្នកដាក់ពាក្យសុំដែលទទួលបានការងារ និងអនុវត្តនីតិវិធីផ្សេងទៀតពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំការងារ

**4.** គោលបំណងទូទៅនៃការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនទាំងអស់

- ការទប់ស្កាត់និងការឆ្លើយតបទៅការក្លែងបន្លំ ការបំពានលើគោលការណ៍ និងវិធានដែលពាក់ព័ន្ធ ការគំរាមកំហែង និងការខូចខាត

- ប្រតិបត្តិការ ការគ្រប់គ្រង និងការកែលម្អគេហទំព័រ គណនីបណ្តាញសង្គម ពាក្យសុំ សកម្មភាពទីផ្សារ ផលិតផល និងសេវាកម្មរបស់យើង
- ការវិភាគទិន្នន័យស្តីពីការចូលប្រើប្រាស់គេហទំព័ររបស់យើង និងខ្លឹមសាររបស់គេហទំព័រ ហើយក៏ដូចជាល្បឿននៃការចូលប្រើ ដោយហេតុនេះទើបមានការខិតខំកែលម្អលើគេហទំព័ររបស់យើង និងខ្លឹមសាររបស់ខ្លួន ហើយដើម្បីធ្វើឱ្យប្រព័ន្ធ និងម៉ាស៊ីនមេរបស់យើងកាន់តែប្រសើរឡើង
- រាល់គោលបំណងផ្សេងទៀត ដែលត្រូវបានជូនដំណឹងជាលក្ខណៈបុគ្គល ឬប្រកាសជាសាធារណៈ ប្រសិនបើមានការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន

## 5. មូលដ្ឋានគតិយុត្តិ

យើងនឹងដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកស្របតាមមូលដ្ឋានគតិយុត្តិដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ មូលដ្ឋានគតិយុត្តិចំពោះដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកអាចផ្លាស់ប្តូរទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃយុត្តាធិការរៀងៗខ្លួន។

## 6. ការបង្ហាញទិន្នន័យផ្ទាល់ខ្លួនទៅអ្នកទទួល

យើងមិនលក់ ឬជួលទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកទេ។ យើងអាចនឹងបង្ហាញទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកទៅអ្នកទទួលដូចដែលបានរៀបរាប់នៅខាងក្រោម ឬបានបកស្រាយនៅក្នុងគោលការណ៍ជាក់លាក់

ក្នុងករណីមានភាពចាំបាច់ក្នុងការបន្តគោលបំណងនៃដំណើរការទិន្នន័យផ្ទាល់ខ្លួនដែលបានកំណត់ក្នុងផ្នែកទី 4 និងស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

1. ក្រុមហ៊ុន

   សាខា និងអង្គភាពពាក់ព័ន្ធ៖ Sumitomo Electric Industries, Ltd. បានចុះបញ្ជីរួមមានជាអាទិ៍ តំណ ខាងក្រោម ("ក្រុមហ៊ុន")។

2. អ្នកផ្តល់សេវា

   ក្រុមហ៊ុនផ្តល់សេវា ដូចជាក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ក្រុមហ៊ុនផ្តល់សេវាវិភាគគេហទំព័រ ក្រុមហ៊ុនផ្តល់សេវាក្លោដ ក្រុមហ៊ុនលក់កម្មវិធីសូហ្វវែរ ក្រុមហ៊ុនផ្តល់សេវាវិភាគស្ថិតិលក់ ភ្នាក់ងារជ្រើសរើសបុគ្គលិកនិងផ្តល់ការងារ ឬអ្នកផ្តល់ឱវាទវិជ្ជាជីវៈ ឬអ្នកពិគ្រោះ។

3. ផ្សេងៗទៀត

   ដៃគូដែលមានសក្តានុពលនៃការរួមបញ្ចូលគ្នា និងការទិញយក អាជ្ញាធរផ្នែកច្បាប់ឬនិយ័តកម្ម ឬភាគីទីបីផ្សេងទៀត។

## 7. ការផ្ទេរឆ្លងដែន

យើងកំពុងចូលរួមក្នុងសកម្មភាពអាជីវកម្មលើមាត្រដ្ឋានសកល ហើយក្នុងករណីខ្លះ យើងនឹងផ្ទេរទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកទៅប្រទេស ឬតំបន់ដែលមិនមានច្បាប់ការពារទិន្នន័យ បទប្បញ្ញត្តិ និងមធ្យោបាយផ្សេងទៀតដែលស្មើនឹងការការពារទិន្នន័យផ្ទាល់ខ្លួននៅក្នុងប្រទេស ឬតំបន់ដែលអ្នករស់នៅ។

SUMITOMO ELECTRIC GROUP

នៅពេលផ្ទេរទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកទៅក្រៅប្រទេស យើងនឹងចាត់វិធានការសមស្របស្របតាមបទប្បញ្ញត្តិដែលបានកំណត់ក្នុងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## 8. ទំហំផ្ទុកមានកំណត់សម្រាប់ទិន្នន័យផ្ទាល់ខ្លួន

ប្រសិនបើមិនមានការចង្អុលបង្ហាញផ្សេងពីនេះទេ យើងនឹងរក្សាទិន្នន័យផ្ទាល់ខ្លួនដែលយើងប្រមូលទាក់ទងនឹងអ្នកសម្រាប់រយៈពេលចាំបាច់ដើម្បីដំណើរការទិន្នន័យផ្ទាល់ខ្លួនបែបនេះ លើកលែងតែក្នុងករណីដែលច្បាប់តម្រូវឱ្យយើងរក្សាទុកទិន្នន័យក្នុងរយៈពេលយូរជាងនេះ ក្នុងករណីនេះយើង នឹងរក្សាវាទុកក្នុងរយៈពេលដែលច្បាប់កំណត់។

ដើម្បីកំណត់រយៈពេលរក្សាទុកសមស្របសម្រាប់ទិន្នន័យផ្ទាល់ខ្លួន យើងពិចារណាទៅលើចំនួន ច្បាប់ដើម និងកម្រិតរសើបនៃទិន្នន័យផ្ទាល់ខ្លួន ហានិភ័យនៃគ្រោះថ្នាក់ដែលអាចកើតមានពីការប្រើប្រាស់ ឬការបង្ហាញទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដែលមិនមានការអនុញ្ញាត គោលបំណងដែលយើងដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក និងថាតើយើងអាចសម្រេចគោលបំណងទាំងនេះតាមរយៈមធ្យោបាយផ្សេងទៀត និងលក្ខខណ្ឌតម្រូវដោយច្បាប់ជាធរមានដែរឬទេ។

## 9. សិទ្ធិរបស់អ្នក

អាស្រ័យលើទីកន្លែងដែលអ្នករស់នៅ អ្នកអាចនឹងមានសិទ្ធិស្របច្បាប់ច្រើនទាក់ទងនឹងទិន្នន័យផ្ទាល់ខ្លួនដែលយើងកាន់ទាក់ទងនឹងអ្នក។ សិទ្ធិទាំងនេះអាចផ្លាស់ប្តូរអាស្រ័យលើទីកន្លែងដែលអ្នករស់

SUMITOMO ELECTRIC GROUP

នៅ ហើយច្បាប់ការពារទិន្នន័យដែលនឹងអនុវត្តចំពោះទំនាក់ទំនងរវាងអ្នក និងយើង ប៉ុន្តែជាធម្មតារួមមានៈ

1. សិទ្ធិក្នុងការទទួលព័ត៌មានទាក់ទងនឹងដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក និងការប្រើទិន្នន័យផ្ទាល់ខ្លួនដែលយើងកាន់ទាក់ទងនឹងអ្នក។
2. សិទ្ធិក្នុងការស្នើសុំឱ្យយើងកែតម្រូវទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកប្រសិនបើវាមិនត្រឹមត្រូវ ឬមិនពេញលេញ
3. សិទ្ធិក្នុងការស្នើសុំឱ្យយើងលុបទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក
4. សិទ្ធិក្នុងការស្នើសុំឱ្យយើងរឹតត្បិតលើដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក
5. សិទ្ធិក្នុងការជំទាស់នឹងពួកយើងអំពីដំណើរការរបស់យើងនៃទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក
6. សិទ្ធិក្នុងការដកការយល់ព្រមរបស់អ្នកចំពោះដំណើរការរបស់យើងលើទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក។ (សិទ្ធិនេះមានតែនៅពេលដែលយើងពឹងផ្អែកលើការអនុញ្ញាតឱ្យដំណើរការទិន្នន័យរបស់អ្នកប៉ុណ្ណោះ។ ការដកការយល់ព្រមមិនប៉ះពាល់ដល់ភាពស្របច្បាប់នៃដំណើរការដោយផ្អែកលើការយល់ព្រមមុនការដករបស់ខ្លួននោះទេ។)

ដរាបណាសំណើរបស់អ្នកដើម្បីអនុវត្តសិទ្ធិរបស់អ្នកស្ថិតនៅក្នុងវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិជាធរមាន អ្នកអាចអនុវត្តសិទ្ធិរបស់អ្នកដោយទាក់ទងមកយើងដោយប្រើព័ត៌មានអំពីពួកយើងនៅក្នុងផ្នែកទី 12 ខាងក្រោម។ សូមចងចាំថាយើងអាចនឹងគិតថ្លៃសេវាសមរម្យដល់អ្នកក្នុងការដំណើរការសំណើរបស់អ្នកម្តង នៅពេលត្រូវបានអនុញ្ញាតដោយច្បាប់ការពារទិន្នន័យជាធរមាន។ ដូចគ្នានេះដែរ

SUMITOMO ELECTRIC GROUP

សូមចងចាំថាអ្នកអាចនឹងត្រូវការដាក់បញ្ចូលព័ត៌មានបន្ថែមមកយើងដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកមុនយើងដំណើរការសំណើរបស់អ្នក។

## 10. សុវត្ថិភាព

ដើម្បីការពារទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកទៅនឹងការបំផ្លាញ ការបាត់បង់ ការប្រើប្រាស់ ឬការកែប្រែដោយចៃដន្យ ឬដោយខុសច្បាប់ និងប្រឆាំងនឹងការបង្ហាញ ឬការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត យើងប្រើប្រាស់វិធានការសុវត្ថិភាពក្រុមហ៊ុន មនុស្ស រូបវន្ត និងបច្ចេកទេសដែលត្រឹមត្រូវ។

## 11. ការផ្លាស់ប្តូរចំពោះគោលការណ៍នេះ

យើងអាចកែប្រែគោលការណ៍នេះពីមួយពេលទៅមួយពេល ហើយនឹងបង្ហោះគោលការណ៍ដែលបានធ្វើបច្ចុប្បន្នភាព រួមជាមួយ កាលបរិច្ឆេទចូលជាធរមានដែល "បានធ្វើបច្ចុប្បន្នភាពចុងក្រោយ" សម្រាប់ការកែប្រែ។ យើងណែនាំអ្នកឱ្យត្រួតពិនិត្យគោលការណ៍នេះឱ្យបានទៀតទាត់។ ប្រសិនបើយើងធ្វើការផ្លាស់ប្តូរខ្លឹមសារចំពោះគោលការណ៍នេះ អ្នកនឹងទទួលបាន សេចក្តីជូនដំណឹងយ៉ាងសមស្រប ដូចជាសេចក្តីជូនដំណឹងដែលបានបង្ហោះលើគេហទំព័ររបស់យើងជាដើម។

## 12. ព័ត៌មានអំពីពួកយើង

1. ឈ្មោះអ្នកគ្រប់គ្រង៖ Sumitomo Electric Industries, Ltd.
2. អាសយដ្ឋានការិយាល័យកណ្តាល៖ 4-5-33, Kitahama, Chuo-ku, Osaka City, Osaka, Japan

3. ឈ្មោះប្រធានគ្រប់គ្រងទិន្នន័យផ្ទាល់ខ្លួន: សូមចុចទីនេះ។

4. ទម្រង់បែបបទសាកសួរ: សូមចុចទីនេះ។

ប្រសិនបើអ្នកមានសំណួរណាមួយទាក់ទងនឹងគោលការណ៍នេះ សិទ្ធិរបស់អ្នក ឬបញ្ហាផ្សេងទៀតទាក់ទងនឹងការការពារទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក  អ្នកអាចទាក់ទងមកយើងដោយប្រើទម្រង់បែបបទសាកសួរនៅខាងលើ។

កាលបរិច្ឆេទមានប្រសិទ្ធភាព៖ ថ្ងៃទី14 ខែមេសា ឆ្នាំ 2023

បានធ្វើបច្ចុប្បន្នភាពចុងក្រោយ៖ ថ្ងៃទី 14 ខែមេសា ឆ្នាំ 2023